**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៤៩ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតគណៈកម្មការអន្តរក្រសួង
# ជំរុញនិងត្រួតពិនិត្យការងារអធិការកិច្ចហត្ថពលកម្មបរទេស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ០៥/នស/រកម/៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអន្តោប្រវេសន៍
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណូមពរចាំបាច់នៃការងារ

## សម្រេច

**ប្រការ១.** _

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងជំរុញនិងត្រួតពិនិត្យការងារអធិការកិច្ចហត្ថពលកម្មបរទេស ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. | ឯកឧត្តមបណ្ឌិត **អ៊ិត សំហេង** | រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| ២. | ឯកឧត្តម **សក់ សេដ្ឋា** | រដ្ឋលេខាធិការប្រចាំការក្រសួងមហាផ្ទៃ | អនុប្រធានទី១ |
| ៣. | ឯកឧត្តម សន្តិបណ្ឌិត **សុខ ផល** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤. | ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** | អគ្គស្នងការនគរបាលជាតិ ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៥. | ឯកឧត្តម **ម៉ឹន ហុន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៦. | ឯកឧត្តម **កោង សុម៉ារិទ្ធ** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៧. | លោកជំទាវ **សុវណ្ណា វណ្ណារតន៍** | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៨. | លោកជំទាវ **ជូ ម៉ិនអេង** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៩. | ឯកឧត្តម **នៅ លក្ខណា** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១០. | ឯកឧត្តម **ប្រាក់ សំអឿន** | អគ្គនាយករដ្ឋបាល ក្រសួងមហាផ្ទៃ | សមាជិក |
| ១១. | ឯកឧត្តម នាយឧត្តមសេនីយ៍ **គៀត ច័ន្ទថារិទ្ធ** | អគ្គនាយកអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ | សមាជិក |
| ១២. | ឯកឧត្តម **សេង សក្ដា** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៣. | អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត | | សមាជិក |
| ១៤. | ឯកឧត្តម នាយឧត្តមសេនីយ៍ **កែវ វណ្ណថន** | អគ្គនាយករងអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ | សមាជិក |
| ១៥. | ឯកឧត្តម ឧត្តមសេនីយ៍ឯក **ឌី វិជ្ជា** | អគ្គស្នងការរងនគរបាលជាតិ ក្រសួងមហាផ្ទៃ | សមាជិក |
| ១៦. | ឯកឧត្តម ឧត្តមសេនីយ៍ឯក **សុវណ្ណា ពិសាខា** | អគ្គនាយករងអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ | សមាជិក |
| ១៧. | ឯកឧត្តម **សួង សទ្ធាវុឌ្ឍី** | ទីប្រឹក្សាអមក្រសួង និងជាអគ្គនាយករង នៃអគ្គនាយកដ្ឋានការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៨. | លោក **ជួប ណារ៉ាត់** | អគ្គនាយករង នៃអគ្គនាយកដ្ឋានការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៩. | លោកឧត្តមសេនីយ៍ទោ **ហាស់ សុត្ថា** | ប្រធាននាយកដ្ឋានជនបរទេសអន្តោប្រវេសន្ត ជាអ្នកវិនិយោគឯកជន ក្រសួងមហាផ្ទៃ | សមាជិក |
| ២០. | ស្នងការ នៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត | | សមាជិក |
| ២១. | ប្រធានមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត | | សមាជិក |

**ប្រការ២.** _

គណៈកម្មការអន្តរក្រសួងជំរុញនិងត្រួតពិនិត្យការងារអធិការកិច្ចហត្ថពលកម្មបរទេស មានតួនាទីភារកិច្ចដូចខាងក្រោម៖

- ដឹកនាំពង្រឹងការងារអធិការកិច្ចហត្ថពលកម្មបរទេសក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យមានប្រសិទ្ធភាពខ្ពស់ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ជំរុញការងារអធិការកិច្ចហត្ថពលកម្មបរទេសនៅតាមសហគ្រាស គ្រឹះស្ថាន កាស៊ីណូ ក្លឹបកម្សាន្តនានា ដើម្បីគាំទ្រដល់ផែនការប្រតិបត្តិការបង្កើនការងារប្រយុទ្ធប្រឆាំងគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- ធ្វើអធិការកិច្ចហត្ថពលកម្មបរទេសនៅតាមសហគ្រាស គ្រឹះស្ថាន កាស៊ីណូ ក្លឹបកម្សាន្តនានា ក្នុងករណីរកឃើញបទល្មើសពាក់ព័ន្ធល្បែងស៊ីសងខុសច្បាប់ ឬការឆបោកតាមប្រព័ន្ធអនឡាញ ឬការជួញដូរមនុស្ស ការជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ឬបទល្មើសសម្អាតប្រាក់ ឬបទល្មើសផ្សេងៗទៀត ត្រូវដឹកនាំណែនាំចាត់វិធានការ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ផ្សព្វផ្សាយគោលការណ៍ វិធានការពាក់ព័ន្ធការងារអធិការកិច្ចហត្ថពលកម្មបរទេសដល់ម្ចាស់ឬនាយកសហគ្រាស គ្រឹះស្ថាន កាស៊ីណូ និងក្លឹបកម្សាន្តនានាឱ្យបានយល់ជ្រួតជ្រាប និងចូលរួមអនុវត្តឱ្យទទួលបានប្រសិទ្ធភាពខ្ពស់
- បំពេញភារកិច្ចផ្សេងៗទៀតតាមការចាំបាច់។

**ប្រការ៣.** _

ប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មការនេះ មានសិទ្ធិចាត់ចែងប្រើប្រាស់មន្ត្រីក្រោមឱវាទឱ្យចូលរួមបំពេញការងារតាមការចាំបាច់។

**ប្រការ៤.** _

ក្នុងការបំពេញការងារ គណៈកម្មការអន្តរក្រសួងជំរុញនិងត្រួតពិនិត្យការងារអធិការកិច្ចហត្ថពលកម្មបរទេស ត្រូវរាយការណ៍ និងសុំយោបល់ដឹកនាំជាប្រចាំពី **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។**

**ប្រការ៥.** _

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៦.** _

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១២កើត ខែ មិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល:</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ